# សេចក្តីសង្ខេបអំពីមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា

| | |
|---|---|
| ការគ្រប់គ្រង | មូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា (TDF) ជាគម្រោងសាកល្បងដែលធ្វើឡើងរួមគ្នាដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៃព្រះរាជាណាចក្រកម្ពុជា (MIME)។ |
| គោលដៅ | បង្កើនភាពប្រកួតប្រជែងរបស់សហគ្រាសធុនតូច និងមធ្យម (SMEs) ដែលស្ថិតនៅក្នុងវិស័យកសិឧស្សាហកម្មផ្នែកចំណីអាហារ ដោយជួយពួកគេអោយមានភាពប្រកួតប្រជែងកាន់តែប្រសើរឡើងតាមរយៈការអភិវឌ្ឍន៍បច្ចេកវិទ្យា និង ការផ្លាស់ប្តូរក្នុងការគ្រប់គ្រងផ្សេងៗ។ |
| ប្រភេទមូលនិធិ | ជាមូលនិធិគ្មានសំណងដែលនឹងត្រូវផ្តល់ជូនដល់គម្រោងរបស់**SMEs**ណាដែលមានលក្ខណៈគ្រប់គ្រាន់តាមការវាយតំលៃរបស់TDF Management Team និងក្រុមអ្នកបច្ចេកទេស។<br>មូលនិធិនេះអាចនឹងត្រូវផ្តល់ជូនតាមលក្ខណៈទូទាត់ជាដំណាក់កាល ។ |
| មូលនិធិដែលអាចផ្តល់ជូន | ពី ៥,០០០ ដល់ ៣០,០០០ ដុល្លាអាមេរិក |
| ការរួមចំណែករបស់SMEs | • **SMEs**ត្រូវរួមចំណែកយ៉ាងតិចបំផុត៥០%នៃការចំណាយលើគម្រោងអភិវឌ្ឍន៍ធុរៈកិច្ចរបស់ខ្លួន។<br>• **SMEs** ជាអ្នកទទួលខុសត្រូវលើរាល់ថ្លៃចំណាយក្នុងការជួលភាគីដទៃមកជួយរៀបចំសំណុំឯកសាររបស់ខ្លួនសំរាប់ដាក់ចូលក្នុងការវាយតំលៃ។<br>• **គ្មានការបង់កំរៃសំរាប់ការចូលរួមស្នើសុំមូលនិធិ (TDF) នេះទេ។** |
| លក្ខខណ្ឌនៃសហគ្រាសដែលអាចទទួលបានមូលនិធិ(TDF) | សហគ្រាសដែលអាចទទួលបានជំនួយTDF ត្រូវបំពេញលក្ខខ័ណ្ឌដូចខាងក្រោម:<br>• ជាសហគ្រាសដែលចុះបញ្ជីត្រឹមត្រូវនៅក្រសួង រឺមន្ទីរ ឧស្សាហកម្ម រ៉ែ និងថាមពល និងមានកម្មករតិចជាង១០០នាក់ និងមានទ្រព្យសកម្មតិចជាង៥០០,០០០ដុល្លាអាមេរិក។ ទ្រព្យសកម្មនេះរាប់បញ្ចូលតែ អាគារ គ្រឿងចក្រ ឧបករណ៍បរិក្ខា មធ្យោបាយដឹកជញ្ជូន និងទុនបង្វិលប៉ុណ្ណោះ។<br>• ម្ចាស់សហគ្រាសត្រូវមានសញ្ជាតិកម្ពុជា ។<br>• ជាសហគ្រាសដែលពាក់ព័ន្ធក្នុងឧស្សាហកម្មកែច្នៃម្ហូបអាហារនិងភេសជ្ជៈ យ៉ាងតិច២ឆ្នាំ។<br>• ស្ម័គ្រចិត្តអនុវត្តតាមមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា លើក្រមសីលធម៌សង្គម។<br>មូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យា នឹងផ្តល់ជូនសហគ្រាស/ក្រុមហ៊ុនដែលមានម្ចាស់រឺអ្នកគ្រប់គ្រងជាស្ត្រី តាមកូតា ៤០-៤៥%។ |
| លក្ខខ័ណ្ឌនៃគំរោងកែលំអអាជីវកម្ម ដែលអាចទទួលបានមូលនិធិ(TDF) | គម្រោងកែលំអត្រូវបំពេញតាមលក្ខខ័ណ្ឌដូចខាងក្រោម:<br>• ផ្តោតលើការកែលំអស្តង់ដារអនាម័យ ហើយនិងពាក់ព័ន្ធនឹងក្បួនអនុវត្តន៍និងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពចំណីអាហារ។មូលនិធិរបស់គម្រោងមូលនិធិអភិវឌ្ឍន៍បច្ចេកវិទ្យានឹងមិនត្រូវបានយកមកប្រើប្រាស់សំរាប់ការសិក្សាស្រាវជ្រាវលើទីផ្សារនិងទស្សនៈកិច្ចសិក្សាទេ។<br>• ការវិនិយោគនឹងលើកស្ទួយបច្ចេកវិទ្យាពាក់ព័ន្ធនឹងការកែលំអប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ(ជារួមមានគ្រឿងបរិក្ខារ គ្រឿងចក្រ ការបណ្តុះបណ្តាល |

| | |
|---|---|
| | ការកែលំអការគ្រប់គ្រង ហើយនិងទទួលកែលំអសំរាប់ទទួលវិញ្ញាបនប័ត្រ ឬភាពអនុលោមស្តង់ដារ អន្តរជាតិលើសុវត្ថិភាពចំណីអាហារ)។<br>• គម្រោងនឹងលើកស្ទួយការកែលំអផលិតភាព និងការបង្កើតអោយមានការកៃច្នៃមួយដ៏សមស្របនិងមានសក្តានុពលភាពលើការលក់ និងប្រាក់ចំណេញ។<br>• គម្រោងបង្ហាញគំរូល្អដែលអាចឲ្យសហគ្រាសក្នុងប្រទេសយកគំរូតាម។ ហើយនិង<br>• គម្រោងមិនពាក់ព័ន្ធនឹងគ្រឿងស្រវឹង និងថ្នាំជក់។<br><br>ដើម្បីបង្កើនភាពប្រកួតប្រជែងសំរាប់ការជ្រើសរើសនេះ នឹងគ្មានការកំណត់ប្រភេទនៃឧស្សាហកម្មកែច្នៃចំណីអាហារទេ ហើយក៏គ្មានការកំណត់ប្រភេទបច្ចេកវិទ្យាដែលSMEs ស្នើក្នុងគម្រោងរបស់គេដែរ។ |
| ដំណើរការអនុម័តលើការផ្តល់ជំនួយមូលនិធិ | ការស្នើសុំជំនួយTDF នឹងត្រូវវាយតំលៃតាមរយៈដំណាក់កាលជ្រើសរើសពីរធំៗ ហើយការស្នើសុំនេះត្រូវបានរំពឹងថានឹងត្រូវធ្វើឡើងចំនួន៤លើក ក្នុងឆ្នាំ ២០១២ និងដើមឆ្នាំ ២០១៣ ប៉ុន្តែនៅក្នុងអំឡុងពេលនៃដំណាក់កាលផ្តល់ហិរញ្ញប្បទានសាកល្បងនៃថវិកាចំនួន ៤០០ ០០០ដុល្លារត្រូវបានប្រើអស់ ការជ្រើសរើសនឹងត្រូវបញ្ឈប់។<br><br>ដំណាក់កាលជ្រើសរើសក្នុងដើមឆ្នាំ ២០១២ នឹងកំណត់យក ១០ សហគ្រាសធុនតូច និងមធ្យម (SMEs)សម្រាប់ការផ្តល់ជំនួយហិរញ្ញប្បទាន។<br><br>**ជំហាននៃការដាក់ពាក្យស្នើសុំជំនួយTDF:**<br>ជំហ៊ានដំបូងពាក់ព័ន្ធនឹងការដាក់**គម្រោងសង្ខេប** (Project Outline)ដ៏សាមញ្ញមួយ ដែលគម្រោងនេះនឹងផ្តល់នូវព័ត៌មានអំពីសហគ្រាសធុនតូច និងមធ្យម(SMEs) និងគម្រោងដែលស្នើសុំសម្រាប់ការវាយតំលៃថាតើព័ត៌មានដែលផ្តល់ជូនទាំងពីរនេះស្របតាមលក្ខណៈវិនិច្ឆ័យនៃសិទ្ធិចូលរួមដែររឺទេ។<br><br>គម្រោងសង្ខេបនឹងត្រូវបានត្រួតពិនិត្យ ហើយSMEs ដែលមានគម្រោងទទួលបានសិទ្ធិ នឹងត្រូវអញ្ជើញឱ្យចូលរួមក្នុងដំណាក់កាលទី២ដើម្បីបំពេញ**ពាក្យស្នើសុំ**(Application)សម្រាប់តម្រូវការព័ត៌មានលំអិតបន្ថែមលើគម្រោងដែលបានដាក់ស្នើ។<br><br>**ពាក្យស្នើសុំ**នឹងត្រូវធ្វើការវាយតំលៃដោយគណៈកម្មាធិការវាយតំលៃហើយពាក្យស្នើសុំល្អបំផុតនឹងត្រូវដាក់បញ្ចូលទៅក្នុងដំណើរការចាប់ឆ្នោតដើម្បីជ្រើសរើសSMEs ដែលនឹងទទួលនូវមូលនិធិហិរញ្ញប្បទាន TDF។ |

| | |
|---|---|
| | ដំណើរការចាប់ឆ្នោតនឹងប្រព្រឹត្តទៅជាសាធារណៈ ហើយSMEsដែលត្រូវបានជ្រើសរើសនឹងត្រូវអញ្ជើញឱ្យចូលរួមដើម្បីបញ្ជាក់ពីតម្លាភាព។ប្រសិនបើនៅក្នុងជំណាក់កាលដេញថ្លៃណាមួយ ចំនួនSMEsដែលបានជ្រើសរើសមានចំនួនតិចជាងឬស្មើនឹងចំនួនកូតា SMEsដែលនឹងត្រូវទទួលបានហិរញ្ញប្បទាននោះនឹងមិនតម្រូវឱ្យមានការចាប់ឆ្នោតទេ ហើយរាល់SMEsដែលត្រូវបានជ្រើសរើសនឹងទទួលបាននូវហិរញ្ញប្បទានដោយស្វ័យប្រវត្តិ។ |
| អ្នកណាជាអ្នកធ្វើការសម្រេចចិត្ត | ដំបូង**គម្រោងសង្ខេប** ត្រូវបានធ្វើការត្រួតពិនិត្យសម្រាប់ទទួលសិទ្ធិចូលរួមដោយក្រុមការងារគ្រប់គ្រងTDF ដែលរួមមានមន្ត្រីMIME និងបុគ្គលិកគម្រោងADBដែលពាក់ព័ន្ធនឹងTDF។<br><br>**រាល់គម្រោងសង្ខេប**នឹងត្រូវបានវាយតំលៃផ្អែកទៅតាមលក្ខណៈវិនិច្ឆ័យសិទ្ធិចូលរួម ហើយធ្វើកំណត់ត្រាអំពីដំណើរការនេះ។ SMEs ដែលត្រូវបានជម្រុះ នឹងត្រូវផ្តល់ជូននូវការឆ្លើយតបជាមួយហេតុផល និងអាចធ្វើការព្យាយាមម្តងទៀតនៅក្នុងជំណាក់កាលជ្រើសរើសលើកក្រោយ។<br><br>**ពាក្យស្នើសុំ**ត្រូវបានវាយតំលៃដោយគណៈកម្មាធិការវាយតំលៃដែលរួមមានមន្ត្រីជាន់ខ្ពស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល(MIME) និងសមាជិកជាប់កិច្ចសន្យាADB នៃក្រុមគ្រប់គ្រងមូលនិធិ និងតំណាងវិស័យឯកជន និងអាជ្ញាធរបច្ចេកទេសពាក់ព័ន្ធ។<br>ពាក្យស្នើសុំត្រូវបានដាក់ពិន្ទុស្របទៅនឹងលក្ខណវិនិច្ឆ័យTDF ហើយអ្នកដែលទទួលបានពិន្ទុ៦៥ ឬច្រើនជាងនេះនៃពិន្ទុសរុប១០០ នឹងត្រូវជ្រើសរើសចូលទៅក្នុងដំណើរការចាប់ឆ្នោតប្រសិនបើមានការតម្រូវ។<br><br>ចំពោះSMEsដែលត្រូវបានផ្តល់ឱ្យនូវមូលនិធិហិរញ្ញប្បទានTDF នឹងត្រូវចុះកិច្ចសន្យាផ្លូវការដែលមានកំណត់នូវលក្ខខណ្ឌនានា។ SMEsដែលទទួលបានជោគជ័យ នឹងតម្រូវឱ្យរក្សាទុកនូវរាល់ឯកសារពាក់ព័ន្ធនិងឯកសារចំណាយក្នុងការប្រើប្រាស់មូលនិធិTDFនិងថវិកាបដិភាគរបស់ពួកគេ ផ្តល់ព័ត៌មានពីលទ្ធផលគម្រោង និងសហការពេញលេញជាមួយនឹងការធ្វើសវនកម្មលើការចំណាយរបស់គម្រោង។ |
| ការតបស្នងលើលទ្ធផលការងារ | បន្ថែមលើមូលនិធិហិរញ្ញប្បទានTDF ដើម្បីជួយដល់ការអនុវត្តគម្រោងធុរៈកិច្ច SMEsដែលទទួលបានជោគជ័យ អាចទទួលបាននូវការតបស្នងលើលទ្ធផលការងាររហូតដល់១០%នៃមូលនិធិTDFដែលបានផ្តល់ឱ្យ ដោយមានកំរិតអតិបរមា ២០០០ ដុល្លារ បន្ទាប់ពីគម្រោងត្រូវបានបញ្ចប់។<br>ការតបស្នងលើលទ្ធផលការងារនឹងត្រូវបានពិចារណា ប្រសិនបើSMEsបានសហការពេញលេញក្នុងការផ្តល់ឱ្យសមាជិកក្រុមTDFនូវព័ត៌មានដែលបានស្នើសុំ និងក្នុងដំណើរការសវនកម្មហាវិញ្ញវត្ថុ។ |

| | |
|---|---|
| ការណែនាំដល់ SMEs | SMEs នឹងទទួលខុសត្រូវលើការរៀបចំទាំងគម្រោងសង្ខេប និងពាក្យស្នើសុំ។ សមាជិកក្រុមគ្រប់គ្រងមូលនិធិ**នឹងមិន**ធ្វើការរៀបចំឯកសារទាំងនេះឲ្យSMEsនោះទេ។<br>លិខិតណែនាំដល់ការបំពេញទំរង់ទាំងពីរនេះនឹងត្រូវផ្តល់ជូនដើម្បីជួយក្នុងដំណើរការរៀបចំ។ រាល់SMEsដែលមានចំណាប់អារម្មណ៍ទាំងអស់នឹងទទួលបាននូវកញ្ចប់ព័ត៌មានដើម្បីជួយពួកគាត់ក្នុងការរៀបចំគម្រោងសង្ខេប។<br>សំនួរសាមញ្ញធម្មតាពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យសិទ្ធិចូលរួម ព័ត៌មាននៅក្នុងគម្រោងសង្ខេប និងពាក្យស្នើសុំ នឹងត្រូវគ្រប់គ្រងដោយក្រុមគ្រប់គ្រងមូលនិធិ។ ប្រសិនបើSMEs ត្រូវការជំនួយលំអិតបន្ថែម ក្រុមគ្រប់គ្រងមូលនិធិអាចចង្អុលណែនាំនូវបុគ្គល ឬស្ថាប័នដ៏ទៃផ្សេងទៀតដែលអាចផ្តល់ជំនួយនេះបាន។ |